# SIREN : របាយការណ៍

**បណ្តាញព័ត៌មានឆ្លើយតបជាយុទ្ធសាស្ត្រ**

**គម្រោងអន្តរភ្នាក់ងារសហប្រជាជាតិស្តីពីការជួញដូរមនុស្ស (UNIAP): ដំណាក់កាលទី ៣**

**ភ្នំពេញ  កម្ពុជា**

ថ្ងៃទី ៣១១ ខែសីហា ឆ្នាំ២០០៧ CB-01

## មូលដ្ឋានទិន្នន័យប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា

| | |
|---|---|
| **ពាក្យគន្លឹះ** | ▪ **ទីកន្លែង:** កម្ពុជា<br>▪ **ប្រធានបទ:** មូលដ្ឋានទិន្នន័យ ព័ត៌មាន<br>▪ **ប្រភេទនៃការវិភាគ:** ការវាយតម្លៃព័ត៌មាន |
| **គោលបំណង** | *កំណត់មូលដ្ឋានទិន្នន័យដែលមានស្រាប់របស់រដ្ឋាភិបាលដែលផ្ទុកព័ត៌មានស្តីពីការជួញដូរមនុស្ស នៅកម្ពុជា និងដើម្បីបង្ហាញអនុសាសន៍សំរាប់ការផ្តល់ជាប្រព័ន្ធនូវព័ត៌មានគួរឱ្យទុកចិត្ត ព័ត៌មានជាគោលដៅនិងស៊ីសង្វាក់គ្នាអំពីស្ថានភាពការជួញដូរមនុស្សពាក់ព័ន្ធនឹងកម្ពុជា ។* |
| **រៀបរៀងដោយ** | UNIAP កម្ពុជា និង IOM កម្ពុជា |

ការបង្កើតប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធិភាព និងនិរន្តរភាព មានសារៈសំខាន់ណាស់ដើម្បីកែលម្អទិន្នន័យ ស្តីពីការជួញដូរមនុស្ស ។ ទិន្នន័យដែលត្រូវប្រមូលត្រូវមាន : (ក) ភាពគួរអោយទុកចិត្ត និងទៀងទាត់ (ខ) ការការពារដើម្បីធានាការសំងាត់ និងសុវត្ថិភាពបុគ្គល (គ) ដែលអាចបម្លែងទៅជាព័ត៌មានដែលមានប្រយោជន៍ដល់អ្នកធ្វើគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត។

នៅកម្ពុជា យ៉ាងហោចណាស់មានក្រសួងប្រាំបួន និងនាយកដ្ឋានដប់ប្រាំដែលដោះស្រាយបញ្ហាការជួញដូរមនុស្ស។ ក្នុងចំណោមស្ថាប័នទាំងនេះ IOM បានរកឃើញប្រព័ន្ធព័ត៌មានដែល “ពាក់ព័ន្ធការជួញដូរមនុស្ស” ដែលប្រតិបត្តិការនៅក្នុងក្រសួងបួន[1] ហើយនៅក្នុងចំណោមប្រព័ន្ធមានទាំងនេះ មានប្រព័ន្ធព័ត៌មានចំនួន៥ដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យនៃការគ្រប់គ្រងទិន្នន័យ ស្តីពីករណីជួញដូរមនុស្ស លំហូរ និងកត្តាហានិភ័យ ។ ទិន្ន័យទាំងនេះគឺ:

**១ មូលដ្ឋានទិន្នន័យនៃការអនុវត្តន៍ច្បាប់ប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរកុមារ**

**(LEASETC)** ដែលគ្រប់គ្រងដោយក្រសួងមហាផ្ទៃ គឺនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនិតិជន។

---

[1] IOM (2007). *ASEAN និងការជួញដូរមនុស្ស*

**២ មូលដ្ឋានទិន្នន័យអំពីករណីបទល្មើសទាំងអស់នៅកម្ពុជា** រួមទាំងករណីជួញដូរមនុស្ស ដែលគ្រប់គ្រងដោយក្រសួងយុត្តិធម៌ ។

**៣ មណ្ឌលសម្របសម្រួលនិងឯកសារ** ដែលមានទិន្នន័យស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយការជួញដូរ ដែលគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតជន និងយុវនិតិសម្បទា ។

**៤ យុទ្ធនាការផ្សព្វផ្សាយព័ត៌មានប្រឆាំងការជួញដូរមនុស្ស** ដែលជាមូលដ្ឋានទិន្នន័យមួយ (ឬចង្កោមទិន្នន័យ) អំពីកត្តាងាយរងគ្រោះរបស់បុគ្គល និងសហគមន៍ ដែលគ្រប់គ្រងដោយក្រសួងកិច្ចការនារី ប៉ុន្តែក្រសួងនេះមិនប្រមូលទិន្នន័យទៀតទេ ។

**៥ ប្រព័ន្ធកត់ត្រាព័ត៌មានពលករចំណាកស្រុក (LMIS)** ជាមូលដ្ឋានទិន្នន័យថ្មីមួយ ដែលទើបង្កើតនាពេលថ្មីៗនេះ សម្រាប់ប្រជាជនកម្ពុជាដែលទៅធ្វើការនៅបរទេស តាមរយៈក្រុមហ៊ុនជ្រើសរើសពលករដែលមានចុះបញ្ជី ។ ប្រព័ន្ធព័ត៌មាននេះត្រូវបានបង្កើតឡើង ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ចំនុចគន្លឹះ:**

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងប្រមូលព័ត៌មាន (ឬបានប្រមូលហើយ) អំពីស្ទើរតែគ្រប់ទិដ្ឋភាពទាំងអស់អំពីការជួញដូរមនុស្សដែលត្រូវការសម្រាប់ប្រព័ន្ធព័ត៌មានស្តីពីការជួញដូរមនុស្ស ដែលរួមមាន:

- កត្តាងាយរងគ្រោះនៅក្នុង ២៤ ខេត្ត
- ចំនួនកម្មករចំណាកស្រុកដែលត្រូវបានបញ្ជូនទៅបរទេស
- ជនរងគ្រោះដែលប៉ូលីសបានកំណត់អត្តសញ្ញាណ
- ជនល្មើសដែលត្រូវបានចាប់ខ្លួន
- ចំនួននៃការផ្តន្ទាទោស
- ការដាក់ទោសបទល្មើស
- ចំនួនជនរងគ្រោះដោយការជួញដូរដែលបានធ្វើមាតុភូមិនិវត្តន៍

- ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ត្រូវប្រមូល វិភាគ និងផ្សព្វផ្សាយព័ត៌មាននេះយ៉ាងទៀងទាត់ដល់អ្នកឆ្លើយតប ដែលពួកគេអាចទទួលប្រយោជន៍ពីព័ត៌មាននេះ។
- ត្រូវបកស្រាយព័ត៌មាន ដោយរួមបញ្ចូលព័ត៌ពីប្រភពផ្សេងៗច្រើនដើម្បីផ្តល់អនុសាសន៍សម្រាប់ការធ្វើអន្តរាគមន៍ និងគោលនយោបាយ ។
- បច្ចុប្បន្ននេះ មិនមានយន្តការរបស់រដ្ឋាភិបាលដើម្បីទទួលទិន្នន័យអំពីជនរងគ្រោះដោយការជួញដូរពីមណ្ឌលផ្តល់ជម្រករបស់អង្គការក្រៅរដ្ឋាភិបាល និងពីអ្នកផ្តល់សេវាជួយជនរងគ្រោះទេ។

***ប្រព័ន្ធព័ត៌មានកម្ពុជាស្តីពីការជួញដូរមនុស្សនៅមាននៅឡើយ ប៉ុន្តែទិន្នន័យពីជនរងគ្រោះ និងករណីជួញដូរ មិនត្រូវបាន គេ វិភាគ ផ្គុំ ឬយោងយ៉ាងប្រទាក់ក្រឡាគ្នាទេ ។***

ខាងក្រោមនេះគឺជាការសង្ខេបអំពីមូលដ្ឋានទិន្នន័យរដ្ឋាភិបាល និងស្ថានភាពរបស់វារហូតមកដល់ខែសីហា ២០០៧:

**១. ការអនុវត្តន៍ច្បាប់ប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរកុមារ (LEASETC)**

- **ស្ថាប័ន: ក្រសួងមហាផ្ទៃ គឺនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន**
- **ប្រភពទិន្នន័យ:** ករណីពាក់ព័ន្ធការជួញដូរនៅក្នុងប្រព័ន្ធផ្លូវច្បាប់កម្ពុជា រួមទាំងករណីអំពើហឹង្សាក្នុងគ្រួសារ និងករណីរំលោភសេពសន្ថវៈ ។
- **ប្រភេទទិន្នន័យ:** ទិន្នន័យអំពីប្រវត្តិរូបរបស់ជនសង្ស័យ និងជនរងគ្រោះ ការចោទប្រកាន់ដែលបានប្ដឹង ព័ត៌មានលម្អិតអំពីការចាប់ខ្លួន ភស្តុតាងពីការធ្វើកោសល្យវិច័យ និងពីការស៊ើបអង្កេត និងការលម្អិតពីសកម្មភាពរបស់តុលាការ ។
- **ស្ថានភាពបច្ចុប្បន្ន:** ទិន្នន័យត្រូវបានប្រមូលដោយនគរបាលខេត្ត បន្ទាប់មកបានបញ្ជូនតាមទូរសារ ទៅភ្នំពេញ ឬត្រូវបានប្រមូលផ្ទាល់ដៃដោយអ្នកជំនាញការដើម្បីវិភាគនៅភ្នំពេញ ។ ការអនុវត្តន៍ជាក់ស្តែងរបស់បណ្ដាញឯកជនក្នុងខេត្តប្រាំអាចនាំផ្លូវដើម្បីបញ្ចូលទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិក នៅប្រភពតែម្តង ថ្វីបើខេត្តដប់ប្រាំបួនទៀតនៅតែប្រើទូរសារបញ្ជូនទិន្នន័យក៏ដោយ ។

**២. មូលដ្ឋានទិន្នន័យពីករណីបទល្មើស**

- **ស្ថាប័ន: ក្រសួងយុត្តិធម៌**
- **ប្រភពទិន្នន័យ:** រាល់ករណីបទល្មើសទាំងអស់នៅកម្ពុជា រួមទាំងករណីជួញដូរមនុស្ស ។
- **ប្រភេទទិន្នន័យ:** ទិន្នន័យអំពីប្រវត្តិរូបរបស់ជនល្មើស និងជនរងគ្រោះ សកម្មភាពតុលាការ ។
- **ស្ថានភាពបច្ចុប្បន្ន:** នេះជាប្រព័ន្ធផ្អែកលើឯកសារដែលក្រដាសទិន្នន័យត្រូវបានបំពេញដោយបុគ្គលិក តុលាការ និងបណ្ដឹងដោយផ្ទាល់ដៃ។ គេបានរៀបផែនការដើម្បីបង្កើតមូលដ្ឋានទិន្នន័យអេឡិចត្រូនិកមួយ ដើម្បីបញ្ចូលទិន្នន័យករណីថ្មីៗ (មិនបញ្ចូលករណីចាស់ៗទេ) ប៉ុន្តែមូលដ្ឋានទិន្នន័យនេះ មិនទាន់បានបង្កើតនៅឡើយទេ ។

**៣. មណ្ឌលសម្របសម្រួល និងឯកសារ**

- **ស្ថាប័ន: ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា**
- **ប្រភពទិន្នន័យ:** ទិន្នន័យពីជនរងគ្រោះដោយការជួញដូរដែលបានធ្វើមាតុភូមិនិវត្តន៍ពីវៀតណាម និងថៃនៅក្រោមក្របខ័ណ្ឌទំនាក់ទំនងទ្វេភាគី ។
- **ប្រភេទទិន្នន័យ:** ទិន្នន័យបរិបទ និងប្រវត្តិរូបពីជនរងគ្រោះ រួមទាំងការលំអិតអំពីដំណើរការជួញដូរ និងទិន្នន័យអំពីជនល្មើស ។

- **ស្ថានភាពបច្ចុប្បន្ន:** មានការពិបាកក្នុងការវិភាគ និងបកស្រាយទិន្នន័យ ដែលប្រមូលបានដោយសារកង្វះខាតសមត្ថភាព ។

**៤. យុទ្ធនាការផ្សព្វផ្សាយព័ត៌មានប្រឆាំងនឹងការជួញដូរមនុស្ស**

- **ស្ថាប័ន: ក្រសួងកិច្ចការនារី**
- **ប្រភពទិន្នន័យ:** ការអង្កេតអំពីអាកប្បកិរិយា និងចំណេះដឹងរបស់អ្នកពាក់ព័ន្ធអំពីការជួញដូរ ផ្លូវជួញដូរ មូលហេតុ និងការយល់ដឹងពីកត្តាងាយរងគ្រោះ ។
- **ប្រភេទទិន្នន័យ:** ទិន្នន័យប្រវត្តិរូប និងទិន្នន័យឯទៀតអំពីអ្នកឆ្លើយតប ព័ត៌អំពីប្រជាជនដែលបានចាកចេញពីភូមិ និងការយល់ដឹងអំពីការជួញដូរមនុស្ស ។
- **ស្ថានភាពបច្ចុប្បន្ន:** ទិន្នន័យត្រូវបានប្រមូល វិភាគ បកស្រាយ និងបានរាយការណ៍នៅឆ្នាំ ២០០៤ ។ បន្ទាប់ពីការអនុវត្តន៍អន្តរាគមន៍តាមគោលដៅ មានការវាយតម្លៃឥទ្ធិពលត្រូវបានធ្វើឡើង ។ ការប្រមូលទិន្នន័យមិនបានបន្តទៀតទេ ។

**5. ប្រព័ន្ធកត់ត្រាព័ត៌មានពលករចំណាកស្រុក (LMIS)**

- **ស្ថាប័ន: ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
- **ប្រភពទិន្នន័យ:** ក្រុមហ៊ុនមានអជ្ញាប័ណ្ណជ្រើសរើសពលករចំនួន ១៣ បានផ្តល់ព័ត៌មានតាមរយៈទម្រង់ ដែលបង្កើត ដោយបុគ្គលិក LMIS អំពីពលករចំណាកស្រុកកម្ពុជាដោយស្របច្បាប់ ។
- **ប្រភេទទិន្នន័យ:** ទិន្នន័យប្រវត្តិរូប និងទិន្នន័យឯទៀតអំពីអ្នកឆ្លើយតប ព័ត៌មានអំពីនិយោជក កិច្ចសន្យា និងព័ត៌មានលម្អិតអំពីការងារ ។
- **ស្ថានភាពបច្ចុប្បន្ន:** LMIS ត្រូវបានសម្ពោធនៅថ្ងៃ ២២ សីហា ឆ្នាំ២០០៧ ។ បន្ទាប់ពីពេលនោះមក បុគ្គលិក LMIS បានចាប់ផ្តើមបញ្ចូលព័ត៌មានគន្លឹះទាំងអស់ពីក្រុមហ៊ុនជ្រើសរើសពលករអំពីពលករចំណាកស្រុកទៅបរទេសនាពេលបច្ចុប្បន្ន និងអនាគត ។

## *កម្ពុជាជិតមានប្រព័ន្ធព័ត៌មានពីការជួញដូរមនុស្សដ៏ងាយយល់បំផុតមួយនៅក្នុងអនុតំបន់មហាមេគង្គ*

នាពេលអនាគត មូលដ្ឋានទិន្នន័យអំពីការជួញដូរមនុស្សនៅកម្ពុជាមានសក្តានុពលភាពផ្តល់នូវរូបភាពស្រដៀងគ្នាច្រើនទៀត អំពីការជួញដូរមនុស្ស និងប្រសិទ្ធិភាពនៃការឆ្លើយតបប្រឆាំងការជួញដូរ ។ មានអនុសាសន៍ដែលអនុវត្តតាមពង្រាង សកម្មភាពដែលអាចប្រកាន់យកដើម្បីឈានឱ្យដល់សក្តានុពលនេះ ។

ដ្យាក្រាមខាងក្រោមនេះបង្ហាញនូវប្រព័ន្ធព័ត៌មានដ៏ល្អអំពីការជួញដូរមនុស្ស ដោយរួមមានគោលបំណងព័ត៌មានគន្លឹះបួនដែលពិពណ៌នាវិសាលភាព និងទំហំនៃស្ថានភាពជួញដូរមនុស្ស និងករណីនានាដែលបានរកឃើញ (ប្រអប់ទី១ និងទី ២) ក៏ដូចជាការឆ្លើយតបប្រឆាំងនឹងការជួញដូរ (ប្រអប់ទី៣ និងទី ៤) ។ នៅក្នុងគោលបំណងព័ត៌មាននីមួយៗ មានគោលដៅព័ត៌មានជាក់លាក់ច្រើនទៀតត្រូវបានស្នើឡើង ។ លទ្ធផលនៃការវិភាគត្រូវបានស្នើឡើងក្នុងប្រអប់ពណ៌ក្រហម ។

# គោលបំណងព័ត៌មាន  និងគោលដៅនៅក្នុងប្រព័ន្ធព័ត៌មានដ៏ល្អឥតខ្ចោះពីការជួញដូរមនុស្ស



**គន្លឹះសម្រាប់ដ្យាក្រាម**

**គោលបំណងព័ត៌មានទី១**-ស្ថានភាពទូទៅនៃការជួញដូរមនុស្សត្រូវបានបំបែកជាករណីបីប្រភេទ ដោយអនុលោមតាមទីកន្លែងដើមរបស់ជនរងគ្រោះដោយការជួញដូរ និងទីកន្លែងកេងប្រវ័ញ្ចលំហូរខាងក្នុង និងលំហូរទៅក្រៅ ។

ក្នុងចំណោមករណីទាំងនោះ (ឧប្បត្តិហេតុទាំងអស់នៃការជួញដូរមនុស្ស) មានតែផ្នែកមួយប៉ុណ្ណោះ ដែលត្រូវបានកំណត់យ៉ាងត្រឹមត្រូវជាផ្លូវការថាជាករណីជួញដូរមនុស្ស ។ រីឯដ៏ទៃទៀតមិនត្រូវបានទទួលស្គាល់ ថាជាករណីជួញដូរ ឬមិនអាចកំណត់បានថាជាករណីជួញដូរទេដោយយោងតាមច្បាប់ជាតិ [សូមមើលA] ដោយមានការកែលម្អឥតឈប់ឈរដើម្បីឆ្លើយតបប្រឆាំងការជួញដូរ សមាត្រនេះនៃករណីជួញដូរ ដែលបានកំណត់យ៉ាងត្រឹមត្រូវគួរមានការកើនឡើងគ្រប់ពេល ។ ដើម្បីយល់ដឹងពីប្រសិទ្ធិភាពនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ជាការសំខាន់ផងដែរត្រូវកែលម្អការយល់ដឹងអំពីស្ថានភាពការជួញដូរមនុស្ស ធ្វើដូច្នេះទើបអាចប៉ាន់ប្រមាណទំហំនៃបញ្ហាបាន ។

គ្រប់ករណីទាំងអស់ដែលត្រូវបានកំណត់ថាជាករណីជួញដូរមនុស្ស មានខ្លះត្រូវបានកំណត់ខុសចំពោះករណីរត់ពន្ធ ករណីចំណាកស្រុកមិនប្រក្រតី ។ល។ ដែលបានចាត់ជាការជួញដូរ [សូមមើល B] ។ ដូច្នេះ **គោលបំណងព័ត៌មានទី២** - ករណីជួញដូរដែលបានកំណត់ ជាធម្មតារួមមានការបូកបញ្ចូលគ្នានៃករណីជួញដូរដែលបានកំណត់យ៉ាងត្រឹមត្រូវ និងមិនត្រឹមត្រូវ ដោយសង្ឃឹមថាសមមាត្រនៃករណីជួញដូរដែលបានកំណត់ខុសមានការថយចុះគ្រប់ពេល ។

បន្ទាប់មក ករណីដែលបូកផ្សំគ្នានេះត្រូវបំពេញក្នុងប្រព័ន្ធគាំទ្រជនរងគ្រោះ ឬប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ និងមូលដ្ឋានទិន្នន័យពាក់ព័ន្ធ [សូមមើល C] ។ ជាចុងក្រោយ ទិន្នន័យដែលបានប្រមូលពីមូលដ្ឋាន ទាំងនេះត្រូវបានគេវិភាគ និងរួមចំណែកដល់លទ្ធផលគ្រឹះដើម្បីជូនព័ត៌មានដល់គោលនយោបាយ និងការធ្វើអន្តរាគមន៍ [សូមមើល D] ជា**គោលបំណងព័ត៌មានទី ៣ និងទី ៤** ។

ការភ្ជាប់ទំនាក់ទំនងនៃមូលដ្ឋានទិន្នន័យកម្ពុជាដែលមានស្រាប់ទៅក្នុងប្រព័ន្ធដ៏ល្អនេះ គេអាចឃើញថា:

- មូលដ្ឋានទិន្នន័យរបស់ LEASETC របស់ក្រសួងមហាផ្ទៃ រួមចំណែកដល់ប្រអប់ទី ២ និងទី ៤ ។

- មូលដ្ឋានទិន្នន័យពីករណីបទល្មើសរបស់ក្រសួងយុត្តិធម៌ ប្រសិនបើចាប់ផ្តើមតាមអេឡិចត្រូនិក វាអាចរួមចំណែកដល់ប្រអប់ ទី ២ និងទី ៤ ។
- មូលដ្ឋានទិន្នន័យរបស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា រួមចំណែកដល់ប្រអប់ទី ១ និងទី ២ ។
- ចង្កោមទិន្នន័យពីការបង្ការ ភាពងាយរងគ្រោះរបស់ក្រសួងកិច្ចការនារី រួមចំណែកដល់ប្រអប់ទី ១ ។
- ប្រព័ន្ធព័ត៌មានពីការចំណាកស្រុកដើម្បីរកការងារនឹងចាប់ផ្តើមរួមចំណែកដល់ប្រអប់ទី១និងទី ២ ។
- មូលដ្ឋានទិន្នន័យអំពីជំរកជាច្រើននៅកម្ពុជានឹងរួមចំណែកដល់ប្រអប់ទី៣ ។

មានការសន្និដ្ឋានបឋមខ្លះដែលអាចធ្វើបានពីការវិភាគនេះ:

- នៅពេលដែលមូលទិន្នន័យច្រើនរួមចំណែកដល់ “ប្រអប់” ដូចគ្នាឬគោលបំណងព័ត៌មាន ត្រូវចងក្រងទិន្នន័យនេះ និងធ្វើឱ្យទិន្នន័យទាំងនេះស៊ីគ្នាដើម្បីការវិភាគយ៉ាងពេញលេញថែមទៀត ។ បន្ទាប់ពីធ្វើដូច្នេះ ហើយ វានឹងអាចបញ្ជាក់ថាតើចង្កោមទិន្នន័យដែលគេកំពុងប្រមូលផ្តល់ព័ត៌មានគួរឱ្យទុកចិត្តសម្រាប់គោលដៅព័ត៌មាននីមួយៗឬទេ ។ ការវិភាគ លទ្ធផលជាគន្លឹះ និងអនុសាសន៍ត្រូវផ្សព្វផ្សាយ ជាសាធារណៈដើម្បីជូនព័ត៌មាន និងកែលម្អគោលនយោបាយនិងអន្តរាគមន៍ (ទាំងរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល) ។
- បើមិនមានការធ្វើសមាហរណកម្មព័ត៌មានគាំទ្រជនរងគ្រោះពីមណ្ឌលផ្តល់ជម្រក និងអ្នកផ្តល់សេវាជួយជនរងគ្រោះឯទៀតទេនោះ យើងនឹងមិនអាចសម្រេចបានរូបភាពយ៉ាងច្បាស់លាស់អំពីការជួញដូរមនុស្សក្នុងស្រុក និងឆ្លងកាត់ព្រំដែន និងការឆ្លើយតបប្រឆាំងនឹងការជួញដូរមនុស្សនៅកម្ពុជាបានទេ។

**អនុសាសន៍បន្ថែម**

១. ទិន្នន័យយុត្តិធម៌ព្រហ្មទណ្ឌតម្រូវការអោយបញ្ចូលទៅក្នុងប្រព័ន្ធអេឡិចត្រូនិក ដើម្បីអោយទិន្នន័យរបស់តុលាការ និងរបស់នគរបាលមានការយោងប្រទាក់ក្រឡាគ្នា ហើយធ្វើការវិភាគយ៉ាងទៀងទាត់ ។

២. ការអនុវត្តន៍ប្រព័ន្ធថ្នាក់ជាតិដែលឆ្លើយតបតាមស្តង់ដារលើចំនួនករណីជនរងគ្រោះដោយការជួញដូរ គួរត្រូវផ្តួចផ្តើមជាដំបូងដោយមន្ត្រីថ្នាក់មូលដ្ឋាន ដោយមានព័ត៌មានស្នូល (ដូចជាថ្ងៃខែឆ្នាំកំណើត និងខេត្ត) ដែលក៏ត្រូវប្រើផងដែរដើម្បីកំណត់អត្តសញ្ញាណករណី ដោយរក្សាការសម្ងាត់ ។ ប្រព័ន្ធមូលដ្ឋានទិន្នន័យក្រោយៗទាំងអស់ គួរបញ្ចូលលេខដូចគ្នា ជាមួយនឹងប្រព័ន្ធចំនួនករណីឯទៀតដែលមានស្រាប់ ។

៣. ត្រូវរក្សាការសម្ងាត់ចំពោះឯកសារគ្រប់គ្រងករណី ដែលអាចបង្ករលក្ខណៈងាយស្រួលដល់ការយោងប្រទាក់ក្រឡាគ្នារវាងអ្នកផ្តល់សេវាផ្សេងៗជាមួយក្រសួង តាមរយៈប្រព័ន្ធលេខករណីដែលស្របតាមស្តង់ដារ ។

៤. ទិន្នន័យពីករណីពិតរបស់ជនរងគ្រោះដោយការជួញដូរ គួរផ្តល់ការយល់ដឹងអំពីកត្តាងាយរងគ្រោះ ជាមួយព័ត៌មានឯទៀតស្តីពីទម្រង់ការជួញដូរមនុស្ស និងនិន្នាការពីអ្នកពាក់ព័ន្ធ អ្នកប្រតិបត្តិ និងប្រភពដទៃទៀត ។

៥. ត្រូវប្រមូលទិន្នន័យ និងត្រូវប្រើដើម្បីការធ្វើសេចក្តីសម្រេចចិត្ត និងកែលម្អអន្តរាគមន៏/សេវា។ ការប្រមូលទិន្នន័យម្តងហើយម្តងទៀត អាចជាបន្ទុកលើជនរងគ្រោះដោយការជួញដូរ លើសហគមន៏ ក៏ដូចជាអ្នកប្រមូលទិន្នន័យផងដែរ ដូច្នេះត្រូវមានគោលបំណងឱ្យច្បាស់លាស់ចំពោះសំនួរនីមួយៗដែលត្រូវសួរ។

*កំណត់ចំណាំលើវិធីសាស្ត្រ*

- *ពិនិត្យឡើងវិញ IOM's ASEAN និងរបាយការណ៏របស់កម្ពុជាអំពីការជួញដូរមនុស្ស ។*
- *ស្វែងរកការពិតថែមទៀតជាមួយរដ្ឋាភិបាល និងដៃគូក្រៅរដ្ឋាភិបាលនៅកម្ពុជា និងនៅថ្នាក់តំបន់ដើម្បីធ្វើបច្ចុប្បន្នភាពស្ថានភាពនៃមូលដ្ឋានទិន្នន័យ ។*

*អំពីអ្នកនិពន្ធ*

*បានបង្កើតឡើងនៅឆ្នាំ ១៩៥១ អង្គការ IOM គឺជាអង្គការអន្តររដ្ឋាភិបាលនាំមុខគេមួយក្នុងវិស័យទេសន្តៈប្រវេសន៏ និងធ្វើការងារយ៉ាងជិតស្និទ្ធជាមួយដៃគូជារដ្ឋាភិបាល អន្តររដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល ។*

*គម្រោងអន្តរទីភ្នាក់ងារសហប្រជាជាតិពីការជួញដូរមនុស្ស (UNIAP) បានបង្កើតឡើងនៅឆ្នាំ ២000 ដើម្បីសម្របសម្រួលឱ្យមានការឆ្លើយតបកាន់តែរឹងមាំ និងកាន់តែសម្របសម្រួលច្រើនទៀតចំពោះការជួញដូរមនុស្សក្នុងអនុតំបន់មហាមេគង្គ ។*

IOM International Organization for Migration

ចំពោះសំនួរ មតិ និងការវាយតម្លៃលើរបាយការណ៍ SIREN នេះ សូមទាក់ទងលោក Paul Buckley តាមរយៈអ៊ីមែល paul.buckley@undp.org.

ដើម្បីព័ត៌មានលំអិតអំពីនិន្នាការ និងការឆ្លើយតបការជួញដូរមនុស្សនៅកម្ពុជា សូមទាក់ទងក្រុម UNIAP កម្ពុជា តាមរយៈលោក លឹម ទិត្យ tith.lim@undp.org និងកញ្ញា Kristy Fleming តាមរយៈអ៊ីមែល kristy.fleming@undp.org

---

**UNIAP: www.no-trafficking.org**